JICA កម្ពុជា

គម្រោងពង្រឹងប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្សវិស័យសុខាភិបាល

The Project for Strengthening Human Resources Development System of Co-medicals

ព្រឹត្តិបត្រព័ត៌មានពីគម្រោង HRD-JICA លេខ ៨ ខែកុម្ភៈ ឆ្នាំ ២០១១

## ដំណើរទស្សនៈកិច្ចនៅសមាគមគិលានុបដ្ឋាក គណៈគិលានុបដ្ឋាក និងមហាវិទ្យាល័យ Saint Louis College នៃប្រទេសថៃ

កាលពីថ្ងៃទី ២៤ ខែមករា កន្លងទៅនេះក្រុមការងារគម្រោងដែលរួមមាន ឯកឧត្តមសាស្ត្រាចារ្យ ធា គ្រុយ រដ្ឋលេខាធិការក្រសួងសុខាភិបាល លោកស្រីគាត ភួង ប្រធាននាយកដ្ឋានអភិវឌ្ឍន៏ធនធានមនុស្សក្រសួងសុខាភិបាល វេជ្ជបណ្ឌិត ទូច សុខនាង អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៏ធនធានមនុស្ស លោកស្រីវេជ្ជបណ្ឌិត Noriko Fujita និង លោកស្រីជំនាញការ Noriko Mochizuki បានធ្វើទស្សនៈ កិច្ចនៅសមាគ មគិលានុបដ្ឋាកនិងគណៈគិលានុបដ្ឋាកនៅ ប្រទេសថៃ។ ដោយហេតុថាការងារគម្រោង ទាក់ទងទៅ នឹងការបង្កើតឱ្យមានច្បាប់និង លិខិតបទដ្ឋានគិលានុបដ្ឋាក ដូច្នេះគោលបំណង នៃទស្សនៈកិច្ចនេះគឺដើម្បីប្រមែប្រមូលព័ត៌ មានទាក់ទងនឹង ច្បាប់និងលិខិតបទដ្ឋាន និង ប្រព័ន្ធចុះបញ្ជីការនៅប្រទេសជិតខាង ដូចជា ប្រទេសថៃ ជាដើម ។ ក្រុមការងារគម្រោងបានធ្វើការស្វែងយល់អំពីតួនាទីនៃសមាគមគិលានុបដ្ឋាក និង គណៈគិលានុបដ្ឋាកប្រទេសថៃ ។ ភាគីថៃ បានពន្យល់អំពីការកំនត់តួនាទី និងលិខិតបទដ្ឋាននៃគិលានុបដ្ឋាកទៅក្រុមការងារផងដែរ។

ឆ្លៀតក្នុងឱកាសនេះ ក្រុមការងារក៏បានធ្វើទស្សនៈកិច្ចនៅមហាវិទ្យាល័យ Saint Louis College ដែលស្ថិតនៅទីក្រុងបាងកក ប្រទេសថៃ នៅថ្ងៃទី ២៩ ខែមករា កន្លងទៅនេះ។ សព្វថ្ងៃនេះ នៅប្រទេសកម្ពុជា កម្មវិធីសិក្សាបរិញ្ញាប័ត្រផ្នែកគិលានុបដ្ឋាក ទើបនឹងបានបើកនៅតាមសាលាមួយចំនួន ប៉ុន្តែនៅមានគ្រូបង្រៀនតិចតួចនៅឡើយដែលមានកម្រិតបរិញ្ញាប័ត្រផ្នែកគិលានុបដ្ឋាក និងជាការលំបាកក្នុងការអនុវត្តន៏កម្មវិធីសិក្សា។ គម្រោងមានផែនការការពង្រឹងសមត្ថភាព គ្រូបង្រៀនតាមរយៈការផ្តល់ឱកាសឱ្យទទួលបានការរៀនបន្ថែមសម្រាប់កម្រិតបរិញ្ញាប័ត្រ Bachelor Bridging Course ដូច្នេះ ហើយទើបក្រុមការងារគម្រោងបានធ្វើទស្សនៈកិច្ចនៅមហាវិទ្យាល័យនេះ ដើម្បីប្រមូលព័ត៌មានដែលពាក់ព័ន្ធ។ មកទល់បច្ចុប្បន្ន មហាវិទ្យាល័យ Saint Louis College បានទទួលនូវនិស្សិតជាច្រើនពីក្នុងប្រទេសក៏ដូចជាក្រៅប្រទេសមកសិក្សា ហើយមហាវិទ្យាល័យនេះក៏មានបរិយាកាសល្អសម្រាប់ការសិក្សា និងអនុវត្តន៏ផងដែរ។ ដូចនេះជាការចាំបាច់ណាស់ក្នុងការគិតគូពីការពង្រឹងពីបរិមាណមកជាគុណភាពវិញ។ ភាគីគម្រោងយល់ឃើញថាការជួយជ្រោមជ្រែងក្នុងការផ្តល់ឱ្យមាន Bridging Course មានសារៈសំខាន់ណាស់ក្នុងការឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនាពេល បច្ចុប្បន្ននេះ។



សមាគមគិលានុបដ្ឋាកថៃ




មហាវិទ្យាល័យ Saint Louis College

# **ការចូលរួមក្នុងវេទិការអន្តរជាតិ** Global Health Workforce Alliance (GHWA) **និងការចាត់វិធានការរបស់ប្រទេសកម្ពុជាចំពោះការបែងចែកធនធានមនុស្សវិស័យសុខាភិបាលទៅតាមតំបន់ដាច់ស្រយាល**

## ១.តើ GHWA ជាអ្វី?

នៅក្នុងបង្កើតប្រព័ន្ធសុខាភិបាលមានកត្តាមូលដ្ឋានចំនួន៤គឺៈ ធនធានមនុស្ស ធនធានសំភារៈ ធនធានហិរិញ្ញវត្ថុ និង ព័តិមាន ។ បើនិយាយ អំពីធនធានមនុស្ស មានវិជ្ជាជីវៈបច្ចេកទេស ដូចជា វេជ្ជបណ្ឌិត ទន្តបណ្ឌិត ឱសថការី គិលានុបដ្ឋាក ឆ្មប បច្ចេកទេសមន្ទីរពិសោធន៏ បច្ចេកទេសវិទ្យុសាស្រ្ត ដែលផ្តល់សេវាសុខាភិបាលជូនដល់ប្រជាជន និង ជាកត្តាចាំបាច់ដែលមិនអាចខ្វះបាន។ ធនធានមនុស្សវិស័យសុខាភិបាលបានក្លាយជា បញ្ហាចំបងរបស់ពិភពលោកជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៏ដែលស្ថានភាពសុខាភិបាលនៅមានកំរិត ។ ដូច្នេះជាការចាំបាច់មួយដែលទាមទារឱ្យមានធនធានមនុស្សវិស័យសុខាភិបាលប្រកបទៅដោយគុណភាព និង ទទួលបានការបណ្តុះបណ្តាលខ្ពស់ធ្វើការនៅតាមកន្លែងដែលមានតម្រូវការ។

តាំងពីឆ្នាំ ២00៤មក បញ្ហាទាក់ទងនឹងកង្វះធនធានមនុស្សវិស័យសុខាភិបាល និងការចែកចាយមិនស្មើគ្នារវាងបុគ្គលិកនៅតាមទីក្រុង និង នៅតាមជនបទ ការធានានូវគុណភាពនៃធនធានមនុស្សវិស័យសុខាភិបាលត្រូវបានទទួលការយកចិត្តទុកដាក់និងបានក្លាយទៅជាប្រធានមួយនៅក្នុងការប្រជុំរបស់អង្គការសុខភាពពិភពលោក។ វេទិការដែលបានប្រព្រឹត្តទៅដើម្បីចូលរួមដោះស្រាយបញ្ហា ធនធានមនុស្សវិស័យសុខាភិបាលអន្តរជាតិត្រូវបានហៅថា Global Health Workforce Alliance ឬសរសេរជាពាក្យកាត់ GHWA ត្រូវបានបង្កើតឡើងនៅឆ្នាំ ២00៦។ GHWA ជាដៃគូជាមួយរដ្ឋាភិបាលនៃប្រទេសជាច្រើន សង្គមស៊ីវិល ភ្នាក់ងារអន្តរជាតិ ស្ថាប័នមូលនិធិ អ្នកស្រាវជ្រាវភាគីដែលទទួលបន្ទុកក្នុងការបណ្តុះបណ្តាល និងសមាគមន៏វិជ្ជាជីវៈ ដែលធ្វើការពិភាក្សា និងការធ្វើការតស៊ូមតិ ក្នុងការស្វែងរកដំណោះស្រាយដែលមានប្រសិទ្ធិភាព ។ ការរៀបចំកម្មវិធីវេទិការ អន្តរជាតិលើកទី ១ បានប្រព្រឹត្តទៅនៅ Kampala Uganda ដែលពេលនោះសេចក្តីប្រកាស Kampala ត្រូវបានថ្លែងជាផ្លូវការ។

## ២. ការចូលរួមក្នុងវេទិការអន្តរជាតិលើកទី ២

នេះគឺជាការរៀបចំវេទិការអន្តរជាតិ GHWA លើកទី ២ ដែលបានប្រព្រឹត្តិទៅនៅទីក្រុងបាងកក ពីថ្ងៃទី ២៤ ដល់ថ្ងៃទី ២៩ ខែមករា ។ ភាគីដែលបានចូលរួមឧបត្ថម្ភរួមមាន Rockefeller Foundation, Mahidon Foundation, World Bank, JICA ។ល។ នៅក្នុងកម្មវិធីនេះ មានការចូលរួមពីសំណាក់មន្ត្រីជាន់ខ្ពស់ក្រសួងសុខាភិបាល និង ក្រសួងដទៃទៀត និងមន្ត្រីសុខាភិបាលដែល ទទួលបន្ទុកក្នុងការអភិវឌ្ឍន៏ធនធានដែលមកពីប្រទេសកំពុងអភិវឌ្ឍន៏ ។ សកម្មភាពតស៊ូមតិ និង ការអន្តរាគមន៏ប្រកប ដោយប្រសិទ្ធិភាពដែលទាក់ទងនឹងធនធានមនុស្សវិស័យសុខាភិបាល ត្រូវបានលើកយកមកពិភាក្សា ។

ក្រសួងសុខាភិបាលប្រទេសកម្ពុជាបានធ្វើការវាយតំលៃលើការបណ្តុះបណ្តាល និង បែងចែកបុគ្គលិកឆ្មប និង គិលានុបដ្ឋាកទៅតាម មណ្ឌលសុខភាពដែលស្ថិតនៅតាមតំបន់ ដាច់ស្រយាល និងការរើសនិស្សិតដែលរៀន ចប់ឱ្យចូល បម្រើការ ។ ឯកឧត្តមសាស្រ្តាចារ្យ ធា គ្រុយ រដ្ឋលេខាធិការក្រសួងសុខាភិបាល និង លោក ស្រីគាត ភួង ប្រធាននាយកដ្ឋានអភិវឌ្ឍន៏ធនធានមនុស្សបានមានប្រសាសន៏ ថា "ប្រទេស ណាក៏ជួប បញ្ហានេះដែរ" ។ វេជ្ជបណ្ឌិត និងគិលានុបដ្ឋាកដែលទទួលបានការបណ្តុះបណ្តាលនៅទីក្រុងមិនចង់ធ្វើការនៅមណ្ឌលសុខភាពតំបន់ជនបទទេ។ នៅប្រទេស



កម្ពុជាមានសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគចំនួន ៤ ដើម្បីជួយសម្រួល និង ទ្រទ្រង់ការបណ្តុះបណ្តាលនិស្សិត នៅតាមតំបន់ដែលសាលាគ្រប់ដណ្តប់ ។ នាពេលបច្ចុប្បន្ននេះ យើងពុំទាន់អាចបើកសាលាឱ្យបានច្រើនឡើយ ជាពិសេសនៅតាមថ្នាក់ខេត្ត ព្រោះយើងពុំទាន់មានធនធានគ្រប់គ្រាន់ដើម្បីធានាឱ្យបាននូវគុណភាពនៃការបណ្តុះបណ្តាល ។ ដោយឡែកវិធានការដែលក្រសួងសុខាភិបាលនៃប្រទេសកម្ពុជាបានចាត់កាលពីឆ្នាំ ២០០២ គឺការបង្កើតជំរើសផ្សេងទៀតនៃកម្មវិធីបណ្តុះបណ្តាល ដែលមានរយៈពេលត្រឹមតែ១ឆ្នាំ ជាពិសេសសម្រាប់និស្សិតដែលមកពីសហគមន៍ ព្រោះពួកគាត់ពុំអាចចាកចេញឆ្ងាយពីគ្រួសារគាត់យូរឡើយ។ ក្រសួងសុខាភិបាលបានការផ្តល់អាទិភាពដល់ជនដែលមកពីតំបន់ដាច់ស្រយាលឱ្យទទួលបានការបណ្តុះបណ្តាល និង ការធ្វើកិច្ចសន្យា រវាងនិស្សិតនិងមន្ទីរសុខាភិបាលខេត្តអំពីការវិលមកបំពេញការងារ បន្ទាប់ពីរៀនចប់។ លើសពីនេះទៅទៀត ក្រសួងសុខាភិបាលបានផ្តល់ជាអាហារូបករណ៏ដល់និស្សិតផងដែរ។ ខ្ញុំដឹងថាប្រជាជនកម្ពុជាភាគច្រើន ពុំចង់ចាកចេញទៅតំបន់ដាច់ស្រយាលទេ ប៉ុន្តែវិធានការក្នុងការរើសបុគ្គលិកដែលមកពីតំបនដាច់ស្រយាលឱ្យមកធ្វើការនៅតំបន់ទាំងនោះ បានទទួលជោគជ័យ។ មកដល់ឆ្នាំ ២០០៩ នេះ យ៉ាងហោចណាស់ ក៏មានគិលានុបដ្ឋាកម្នាក់ និងឆ្មប ម្នាក់ធ្វើការនៅតាមមណ្ឌលសុខភាព នៅទូទាំងប្រទេស។ ការអភិវឌ្ឍន៏ធនធានមនុស្សវិស័យសុខាភិបាល និង ការបែងចែកបុគ្គលិកបានក្លាយជាប្រធានបទមួយ។ ប៉ុន្តែការបែងចែកបុគ្គលិក និង ការដោះស្រាយបញ្ហាធនធានមនុស្សវិស័យសុខាភិបាល ត្រូវបានធ្វើការពិចារណាតាំងពីដំណាក់ការនៃការបណ្តុះបណ្តាលមកម្ល៉េះទើបអាចទទួលបាននូវប្រសិទ្ធិភាព ។ វិធានការនេះ ត្រូវបានធ្វើការកត់សំគាល់ និងចាប់អារម្មណ៏ ពីអង្គពិធី ទាំងមូល។

Please see the project homepage:
http://www.jica.go.jp/project/cambodia/004/index.html